00535834

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 21 / 06 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

លេខ / No: D365/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

លេខសំណុំរឿង: ០០២/១៩-០៩-២០០៧/អ.វ.ត.ក.--ក.ស.ច.ស.

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 06 / 2010
ម៉ោង (Time/Heure): 15:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ចំពោះមុខ ៖ **ចៅក្រម យូ ប៊ុនឡេង**

**ចៅក្រម Marcel LEMONDE**

កាលបរិច្ឆេទ ៖ **ថ្ងៃទី២១ ខែ មិថុនា ឆ្នាំ២០១០**

ភាសា ៖ **ខ្មែរ/អង់គ្លេស**

ចំណាត់ថ្នាក់ឯកសារ ៖ **សាធារណៈ**

---

# ដីកាសម្រេចឆ្លើយតបនឹងសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលឯកសារតស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត

---

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ជនត្រូវចោទ**

នួន ជា

ខៀវ សំផន

អៀង សារី

កាំង ហ្គេកអ៊ាវ ហៅ ឌុច

អៀង ធីរិទ្ធ

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

នី ច័ន្ទឌី
ឡោ ជុនធី
គង់ ពិសី
ហុង គីមសួន
យ៉ុង ផានិត
គីម ម៉េងឃី
ម៉ុំ សុវណ្ណារី
ស៊ិន សុវ៌ន
ជេត វណ្ណលី
ពេជ អង្គ
Phillipe CANONNE
Elizabeth Rabesandratana
Mahdev MOHAN
Olivier BAHOUGNE
Martine JACQUIN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BAUDOIN
Lyma Thuy NGUYEN

**មេធាវីការពារក្ដី**

សុន អរុណ Michiel PESTMAN
Victor KOPPE
អាង ឧត្តម Michael G.KARNAVAS
ផាត់ ពៅស៊ាង Diana ELLIS
ស សូវ៉ាន Jacques VERGÈS

00535835

០០២/១៩-០៩-២០០៧/អ.វ.ត.ក.--ក.ស.ច.ស. លេខ/No: D365/3

Silke STUDZINSKY
Françoise GAUTRY
Isabelle DURAND
Pascal AUBOIN

Marie Guiraud
Laure DESFORGES
Christine MARTINEAU
Ferdinand Djammen-Nzepa

ការ សាវុត្ត François ROUX
Marie-Paule CANIZARÈS
Philippe GRÉCIANO

យើង **យូ ប៊ុនឡេង** និង **Marcel LEMONDE** (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញការស៊ើបសួរលើឈ្មោះ **នួន ជា** និង **ជនផ្សេងទៀត** ដែលត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យចំពោះ **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម និង ការវាយប្រហារលើសាសនា** បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និង មាត្រា ២០៩ មាត្រា ២១០ មាត្រា ៥០០ មាត្រា ៥០១ មាត្រា ៥០៣ ដល់ មាត្រា ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦

បានឃើញវិធាន ៥៥(១០) និង ៧៧(១៤) នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក. ("វិធានផ្ទៃក្នុង")

បានឃើញសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងអាចជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១០ ("សំណើសុំ")[1]

បានឃើញដីកាសម្រេចសហចៅក្រមស៊ើបអង្កេតស្តីអំពីសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងអាចជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១០ ("ដីកាសម្រេច")[2]

---

[1] D365
[2] D365/1

00535837



បានឃើញសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចសហចៅក្រមស៊ើបអង្កេតស្តីអំពីសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងអាចជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១០ ("សាលដីកា")[3]

**សំអាងហេតុនៃសេចក្តីសម្រេច**

១. សហចៅក្រមស៊ើបអង្កេតត្រូវបានបង្គាប់ដោយអង្គបុរេជំនុំជម្រះឲ្យធ្វើការពិនិត្យឡើងវិញលើដីកាសម្រេចរបស់ខ្លួន "*ដែលបានប្រព្រឹត្តកំហុសឆ្គងផ្នែកច្បាប់ ដោយសារតែកថាខណ្ឌទីប្រាំនៃដីកាសម្រេចនោះ ពុំបានបង្ហាញសម្អាងហេតុអំពីការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការដែលពួកគាត់សម្រេចបដិសេធឯកសារទាំងឡាយ ដូចមានយោងក្នុងសំណើនោះ ។*"[4]

២. នៅក្នុងសាលដីកាត្រង់កថាខណ្ឌ ២១ អង្គបុរេជំនុំជម្រះបានលើកឡើងថា ៖

*សេចក្តីសង្ខេបនៃកថាខណ្ឌទីប្រាំដែលជាកថាខណ្ឌគោល ពាក់ព័ន្ធនឹងការបដិសេធឯកសារទាំងនោះ បញ្ជាក់ថា មិនអាចមានមូលដ្ឋានពិតប្រាកដសម្រាប់ការពិចារណាចំពោះឯកសារ ដែលបានកំណត់អត្តសញ្ញាណរួចហើយទាំងនោះទេ ។ ជាឧទាហរណ៍ ពួកគេពុំអាចធ្វើការបញ្ជាក់បានថាតើឯកសារណាខ្លះដែលត្រូវបានបដិសេធ ដោយផ្អែកលើមូលដ្ឋាននៃភាពខ្វះ "ភាពពាក់ព័ន្ធនៅក្រោមវិសាលភាពនៃកិច្ចស៊ើបសួរបច្ចុប្បន្ន" និងថាតើឯកសារណាខ្លះដែល "ត្រូវបានសម្រេចថា ជាឯកសារដែលរៀបរាប់តែអំពីបញ្ហាទូទៅពេក" នោះ ។*

៣. តាំងពីដើមដំបូងមក សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ថា ឯកសារដែលជាកម្មវត្ថុនៃសំណើសុំរួមមានអត្ថបទសារព័ត៌មានក្នុងសម័យកាលនោះ ដែលមាននៅក្នុងប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ និងនិយាយអំពីប្រធានបទជាច្រើនផ្សេងៗគ្នា ។ អត្ថបទសារព័ត៌មានគឺជាប្រភពភស្តុតាងសាធារណៈដែលមានលក្ខណៈបន្ទាប់បន្សំ ដែលសរសេរដោយអ្នកសារព័ត៌មាន ដែលឋិតនៅក្រៅប្រទេសក្នុងអំឡុងពេលនោះ ដូច្នេះអត្ថបទទាំងនោះទំនងជាត្រូវបានសរសេរដោយផ្អែកលើប្រភពព័ត៌មានមិនផ្ទាល់ ។

[3] D365/2/10

[4] សាលដីកា កថាខណ្ឌ ២៦

ហេតុដូចនេះ គុណតម្លៃជាភស្តុតាងនៃអត្ថបទទាំងនេះមានកំរិតទាបជាងខ្លាំង ប្រសិនបើប្រៀបធៀបជាមួយភស្តុតាងផ្ទាល់ដែលសហចៅក្រមស៊ើបអង្កេតទទួលបាន ។

៤. សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់បន្ថែមទៀតថា ថ្មីៗនេះអង្គបុរេជំនុំជម្រះទើបបានសម្រេចនៅក្នុងសាលដីកាមួយផ្សេងទៀតទាក់ទងនឹងការដាក់ឯកសារចូលក្នុងសំណុំរឿង ថា៖ ដើម្បីអាចឲ្យសហចៅក្រមស៊ើបអង្កេតអាចបំពេញភារកិច្ចស្វែងរកការពិតទាក់ទងនឹងអង្គហេតុដែលឋិតក្រោមការស៊ើបសួរ បានពេញលេញ គឺត្រូវពិចារណាលើភាពពាក់ព័ន្ធនៃរាល់ភស្តុតាងទាំងអស់ ដើម្បីធ្វើការវាយតម្លៃថាតើ ភស្តុតាងទាំងនោះអាចជួយដល់ការស្វែងរកការពិតដែរ ឬទេ[5] ។ ក្នុងន័យនេះ សហចៅក្រមស៊ើបអង្កេតយល់ថា ដើម្បីសម្រេចថាតើភស្តុតាងណាមួយអាចជួយដល់ការស្វែងរកការពិត គឺត្រូវធ្វើការបង្ហាញថា ភស្តុតាងនោះពាក់ព័ន្ធនឹងអង្គហេតុដែលជាកម្មវត្ថុនៃការស៊ើបសួរ ។ និយាយបែបសាមញ្ញ គឺការស៊ើបសួរត្រូវតែបង្ហាញឲ្យឃើញនូវការពិត ។ ដូច្នេះ ការស៊ើបសួរត្រូវផ្តោតតែទៅលើអង្គហេតុដែលប្តឹងមក ហើយដែលត្រូវបង្ហាញការពិតអំពីអង្គហេតុទាំងនេះ ដោយមិនត្រូវចាប់អារម្មណ៍ជាមួយនឹងអង្គហេតុផ្សេងៗដែលមិនមានភាពពាក់ព័ន្ធ ព្រោះការពិតទាក់ទងនឹងអង្គហេតុទាំងនេះមិនត្រូវបានទាមទារឲ្យបង្ហាញនោះទេ ។

៥. ដោយបានពិចារណាលើអ្វីដែលបានរៀបរាប់មកខាងលើ នៅក្នុងកថាខណ្ឌ ៤ នៃដីកាសម្រេចសហចៅក្រម ស៊ើបអង្កេតបានបញ្ជាក់អំពីឯកសារស្នើសុំណាខ្លះ ដែលត្រូវបានចាត់ទុកថា ពាក់ព័ន្ធជាមួយនឹងវិសាលភាពនៃការស៊ើបសួរ (ការជម្លៀសចេញពីទីក្រុងភ្នំពេញ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការទទួលខុសត្រូវរបស់ជនត្រូវចោទរូបណាមួយ ។ល។) ហើយបានសម្រេចទទួលយកឯកសារទាំងនេះដាក់ចូលក្នុងសំណុំរឿង ។

៦. ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតរកឃើញថា ឯកសារមួយចំនួនទាក់ទងនឹងអង្គហេតុដែលមិនឋិតនៅក្នុងវិសាលភាពនៃការស៊ើបសួរ ដោយសារវាមិននិយាយទាក់ទងនឹងទីកន្លែងឧក្រិដ្ឋកម្មជាក់លាក់ណាមួយ ឬមិនបាននិយាយអំពីអង្គហេតុដែលប្តឹងមកសហចៅក្រមស៊ើបអង្កេតក្នុងកំរិតទូទាំង

---

[5] D313/2/2 សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចសហចៅក្រមស៊ើបអង្កេតស្តីអំពីសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿងធ្វើឡើងថ្ងៃ ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ២៨ (សម្ងាត់)

ប្រទេស ឬដោយសារតែវាមិនមាននូវព័ត៌មានដែលអាចជួយដល់ការកំណត់អំពីធាតុផ្សំបទល្មើស ឬទំរង់នៃការទទួលខុសត្រូវ ។ ដើម្បីឱ្យកាន់តែច្បាស់ជាងនេះ សហចៅក្រមស៊ើបអង្កេតសូមយោងដល់ឯកសារលេខ ១៩៨ ដែលជាអត្ថបទចុះផ្សាយនៅក្នុងសារព័ត៌មាន Los Angeles Times នៅក្នុងខែឧសភា ឆ្នាំ ១៩៧៨ និយាយអំពីដំណើរទស្សនកិច្ចរបស់អតីតយុទ្ធជននៃសង្គ្រាមលោកលើកទីពីរ ទៅកាន់វិទ្យាល័យមួយនៅ San Francisco ដើម្បីនិយាយប្រាប់សិស្សអំពីបទពិសោធន៍របស់គាត់ក្នុងការរំដោះជំរុំប្រមូលផ្តុំ Dachau ហើយដែលក្នុងនោះ គាត់បានអធិប្បាយថា សិស្សៗមិនបានបង្ហាញការចាប់អារម្មណ៍អំពីចំនួនអ្នកស្លាប់នៅក្នុងប្រទេសកម្ពុជានោះទេ ។

៧. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ប្រសិនបើភស្តុតាងណាមួយ ជាពិសេសភស្តុតាងដែលមានគុណតម្លៃជាភស្តុតាងតិចតួច ដូចជាអត្ថបទសារព័ត៌មានជាដើម មិនបានបញ្ជាក់ច្បាស់លាស់អំពីអង្គហេតុដែលពាក់ព័ន្ធនោះទេ នោះវាមិនអាចត្រូវបានចាត់ទុកថាជាភស្តុតាងដែលអាចជួយដល់ការបង្ហាញការពិតចំពោះអង្គហេតុនៃសំណុំរឿង ០០២ នោះឡើយ ។ ហេតុដូច្នេះ ការដាក់ចូលក្នុងសំណុំរឿងនូវឯកសារដែលមានក្នុងឧបសម្ព័ន្ធ “ក” ភ្ជាប់ក្នុងដីកាសម្រេចនេះ ត្រូវបានបដិសេធដោយឈរលើមូលដ្ឋានខាងលើនេះ ។

៨. ទាក់ទងនឹងឯកសារដែលត្រូវបានកំណត់ថា បានលើកឡើងអំពីបញ្ហាដែលមានលក្ខណៈទូទៅពេក សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ទោះបីជាឯកសារទាំងនេះអាចនឹងចូលទៅក្នុងវិសាលភាពនៃការស៊ើបសួរ ខណៈដែលវាមិនមាននូវការរៀបរាប់លំអិត ភាពច្បាស់លាស់ ឬខ្លឹមសារដែលមានតម្លៃជាភស្តុតាងក៏ពិតមែន ក៏សហចៅក្រមស៊ើបអង្កេតយល់ថា វាមិនអាចនឹងជួយដល់ការបង្ហាញការពិត លើសពីការយល់ដឹងជាទូទៅធម្មតាអំពីអង្គហេតុនោះទេ ។ ដើម្បីឱ្យជាក់ច្បាស់ សហចៅក្រមស៊ើបអង្កេតសូមយោងដល់ឯកសារលេខ ២១៤ ដែលជាអត្ថបទដកស្រង់ចេញពីសៀវភៅរបស់លោក Francois Ponchaud “កម្ពុជា ឆ្នាំសូន្យ” បោះពុម្ពនៅក្នុងសារព័ត៌មាន Washington Post ឆ្នាំ ១៩៧៨ ហើយដែលសៀវភៅនេះត្រូវបានគេរិះគន់ថាជាស្នាដៃបែបអក្សរសិល្ប៍[6] ។

---

[6] ទោះបីជាមានការរិះគន់អំពីតម្លៃជាភស្តុតាងនៃសៀវភៅនេះក្តី *“កម្ពុជា ឆ្នាំសូន្យ”* របស់លោក Ponchaud ត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងរួចហើយ (IS4.37) ហើយអ្នកនិពន្ធរូបនេះក៏ត្រូវបានស្តាប់ចម្លើយដោយសហចៅក្រមស៊ើបអង្កេតរួចហើយដែរ (D133)

00535840



៩. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ប្រសិនបើភស្តុតាងណាមួយ ជាពិសេសភស្តុតាងដែលមានគុណតម្លៃជាភស្តុតាងតិចតួច ដូចជាអត្ថបទសារព័ត៌មានជាដើម បានលើកឡើងអំពីអង្គហេតុក្នុងលក្ខណៈទូទៅ នោះវាមិនអាចត្រូវបានចាត់ទុកថាជាភស្តុតាងដែលអាចជួយដល់ការ បង្ហាញការពិតចំពោះអង្គហេតុនៃសំណុំរឿង ០០២ នោះឡើយ ។ ហេតុដូច្នេះ ការដាក់ចូលក្នុងសំណុំរឿងនូវឯកសារដែលមានក្នុងឧបសម្ព័ន្ធ “ខ” ភ្ជាប់ក្នុងដីកាសម្រេចនេះ ត្រូវបានបដិសេធដោយឈរលើ មូលដ្ឋានខាងលើនេះ ។

១០. យោងតាមហេតុផលទាំងអស់ខាងលើ សហចៅក្រមស៊ើបអង្កេតសម្រេចធ្វើការតំកល់ដីកាសម្រេចរបស់ខ្លួន ហើយបដិសេធមិនដាក់បញ្ចូលឯកសារដែលត្រូវបានបដិសេធរួចហើយ ទៅក្នុងសំណុំរឿង ដដែល ។

## អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតសម្រេច ៖

- តំកល់ដីកាសម្រេចដែលបានធ្វើកាលពីពេលមុនតាមដែលហេតុផលដូចមានបញ្ជាក់ខាងលើ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១០

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-juges d'instruction**

**Marcel LEMONDE**

យូ ប៊ុនឡេង